**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ............ សហវ. ......

ថ្ងៃ ............ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី...... ខែ...... ឆ្នាំ២០១៩

**ជម្រាបជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**កម្មវត្ថុ** : ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យាស្តីពីការងារជួសជុលផ្លូវដោយក្រាលកៅស៊ូ DBST ប្រវែង ២១គ.ម ទទឹង ៩ម កាត់ដីកប្រឡាយតាមបណ្តោយផ្លូវ ប្រវែង ១៥ ៥៤០ម និងគូសគំនូសសញ្ញាចរាចរណ៍ ទំហំ ៦ ១៦៩ម² ស្ថិតនៅលើកំណាត់ផ្លូវជាតិលេខ៤៨ ចន្លោះគ.ម០០+០០០ ដល់គ.ម៣៩+១៥០ ក្នុងឃុំបឹងព្រាវ ស្រុកស្រែអំបិល និងឃុំកណ្តោល ស្រុកបុទុមសាគរ ខេត្តកោះកុង។

**យោង** :
- លិខិតលេខ១២៣៣០ សហវ.អថ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កំណត់ហេតុចរចាថ្លៃថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ របស់ គ.ល ក្រសួងសាធារណការ និងដឹកជញ្ជូន
- លិខិតលេខ៥៨២ សក.អល ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រីជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រគល់កិច្ចសន្យាជូននាយកដ្ឋានគ្រឿងចក្រ និងស្ថាបនាផ្លូវ ដើម្បីធ្វើការងារជួសជុលផ្លូវដោយក្រាលកៅស៊ូ DBST ប្រវែង ២១គ.ម ទទឹង ៩ម កាត់ដីកប្រឡាយតាមបណ្តោយផ្លូវ ប្រវែង ១៥ ៥៤០ម និងគូសគំនូសសញ្ញាចរាចរណ៍ ទំហំ ៦ ១៦៩ម² ស្ថិតនៅលើកំណាត់ផ្លូវជាតិលេខ៤៨ ចន្លោះគ.ម០០+០០០ ដល់គ.ម៣៩+១៥០ ក្នុងឃុំបឹងព្រាវ ស្រុកស្រែអំបិល និងឃុំកណ្តោល ស្រុកបុទុមសាគរ ខេត្តកោះកុង ក្នុងតម្លៃសរុបចំនួន ១៣.២០២.០០០.០០០រៀល (ដប់បីប៊ីលានពីររយពីរលានរៀលគត់) ជាតម្លៃកិច្ចសន្យា។

ការជួលបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបាន ត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្ត ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមទេសរដ្ឋមន្ត្រីជ្រាប និងមានវិធានការអនុវត្តបន្តឱ្យសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ។

សូមឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលនូវគារវកិច្ចពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

ចម្លងជូន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- សាលាខេត្តកោះកុង
- នាយកដ្ឋានគ្រឿងចក្រ និងស្ថាបនាផ្លូវ
- នាយកដ្ឋានបច្ចេកទេសសាធារណការ និងដឹកជញ្ជូន
- មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកោះកុង
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តកោះកុង
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798